ផ្សារមូលបត្រកម្ពុជា
CSX
ក្រុមហ៊ុន ផ្សារមូលបត្រកម្ពុជា

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# សេចក្តីជូនព័ត៌មាន
# អំពី
# សេចក្តីសម្រេចលើពាក្យស្នើសុំពិនិត្យលទ្ធភាពអាចចុះបញ្ជីរបស់ក្រុមហ៊ុនភ្នំពេញអេសអ៊ីហ្សិតភីអិលស៊ី (Phnom Penh SEZ Plc.)

ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា (**ផ.ម.ក**) បានសម្រេចឯកភាពជាគោលការណ៍លើពាក្យស្នើសុំពិនិត្យលទ្ធភាពអាចចុះបញ្ជីរបស់ក្រុមហ៊ុនភ្នំពេញអេសអ៊ីហ្សិត ភីអិលស៊ី (Phnom Penh SEZ Plc.) នៅថ្ងៃទី១៨ ខែសីហា ឆ្នាំ ២០១៥។ ដើម្បីអាចចុះបញ្ជីនិងជួញដូរមូលបត្រជាផ្លូវការបាននៅ **ផ.ម.ក.** ក្រុមហ៊ុនត្រូវតែទទួលបានការអនុញ្ញាតអោយបោះផ្សាយមូលបត្រជាសាធារណៈពីគណៈកម្មការមូលបត្រកម្ពុជា (**គ.ម.ក.**) ហើយក្រុមហ៊ុនត្រូវបំពេញនូវលក្ខខណ្ឌតម្រូវផ្សេងៗមួយចំនួនទៀតពាក់ព័ន្ធនឹងការចុះបញ្ជីនៅ **ផ.ម.ក.**។

សូមបញ្ជាក់ជូនថា: ក្រុមហ៊ុនភ្នំពេញអេសអ៊ីហ្សិត ភីអិលស៊ី (Phnom Penh SEZ Plc.) ជាក្រុមហ៊ុនសក្តានុពលមួយដែលវិនិយោគលើអាជីវកម្មសួនឧស្សាហកម្ម ដែលក្នុងនោះសកម្មភាពអាជីវកម្មចម្បងរបស់ក្រុមហ៊ុនគឺ បង្កើត អភិវឌ្ឍ និងដំណើរការតំបន់សេដ្ឋកិច្ចពិសេស ហើយក្រុមហ៊ុនកំពុងគ្រប់គ្រងនិងដំណើរការតំបន់សេដ្ឋកិច្ចពិសេសភ្នំពេញ ដែលជាតំបន់សេដ្ឋកិច្ចពិសេសដ៏ធំមួយនៅក្នុងប្រទេសកម្ពុជា និងដែលមានទីតាំងនៅតាមបណ្តោយផ្លូវជាតិលេខ៤ សង្កាត់កន្ទោក ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ។

ផ្សារមូលបត្រកម្ពុជា CSX Cambodia Securities Exchange